រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់
## ស្តីពី
## ការបង្កើតតែមប្រិ៍សារពើពន្ធ

មាត្រា ១.- ត្រូវបានបង្កើតតែមប្រិ៍សារពើពន្ធ ។
តំលៃតែមប្រិ៍សារពើពន្ធមាន ៤ ប្រភេទ :

- សន្លឹកតែមប្រិ៍មានតំលៃ ១០៛ "ដប់រៀល"
- សន្លឹកតែមប្រិ៍មានតំលៃ ២០៛ "ម្ភៃរៀល"
- សន្លឹកតែមប្រិ៍មានតំលៃ ៥០៛ "ហាសិបរៀល"
- សន្លឹកតែមប្រិ៍មានតំលៃ ១០០៛ "មួយរយរៀល"

មាត្រា ២.- ចំណូលដែលបានមកពីតែមប្រិ៍សារពើពន្ធ ត្រូវបង់ចូលថវិការដ្ឋ ។

មាត្រា ៣.- ក្រសួងហិរញ្ញវត្ថុ មានភារកិច្ចបោះពុម្ពតែមប្រិ៍សារពើពន្ធ សំរាប់អោយប្រើប្រាស់ក្នុងទូទាំងប្រទេស ។

មាត្រា ៤.- ជនណាដែលក្លែងតែមប្រិ៍សារពើពន្ធគ្រប់ប្រភេទ ឬប្រើប្រាស់តែមប្រិ៍សារពើពន្ធដែលក្លែងគ្រប់ប្រភេទដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពី ១០០.០០០៛ "មួយសែនរៀល" ដល់ ១.០០០.០០០៛ "មួយលានរៀល" ។

ប្រាក់ដែលរកប្រមូលបានពីអំពើល្មើសខាងលើនេះ ព្រមទាំងឧបករណ៍ និង សំភារៈផ្សេងៗ ដែលប្រើប្រាស់សំរាប់ប្រព្រឹត្តបទល្មើស ត្រូវរឹបអូសជាកម្មសិទ្ធិរដ្ឋ ឬ ត្រូវបំផ្លាញចោល ។

មាត្រា ៥.- ជនណាប្រើប្រាស់ដោយចេតនានូវតែមប្រិ៍សារពើពន្ធគ្រប់ប្រភេទ ដែលប្រើប្រាស់ម្តងរួចហើយ ត្រូវពិន័យជាប្រាក់ពី ២.០០០៛ "ពីរពាន់រៀល" ដល់ ២០.០០០៛ "ពីរម៉ឺនរៀល" ។

មាត្រា ៦.- តំណាង ឬ ភ្នាក់ងារអាជ្ញាធរណាដែលបង្ខំទារ ឬ ទទួលយកប្រាក់តែមប្រិ៍សារពើពន្ធគ្រប់ប្រភេទដែលគ្មានចែងក្នុងច្បាប់ ឬ ដែលលើសពីការកំណត់ក្នុងច្បាប់ ត្រូវផ្តន្ទាទោស :

Collection by VCAT Professional Consultant

១- ដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើសមាន ចំនួនតិចជាង ១០.០០០រ (មួយម៉ឺនរៀល) ។

២- ដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើសមាន ចំនួនពី ១០.០០០រ (មួយម៉ឺនរៀល) ដល់ ១០០.០០០រ (មួយសែនរៀល) ។

៣- ដាក់ពន្ធនាគារពី ១០ឆ្នាំ ឡើងទៅរហូតដល់អស់មួយជីវិត បើកំរៃដែល បានមកពីអំពើល្មើសមានចំនួនលើសពី ១០០.០០០រ (មួយសែនរៀល) ឡើង ទៅ ។

ប្រាក់កំរៃដែលបានមកពីអំពើល្មើសខាងលើនេះ ត្រូវប្រគល់អោយម្ចាស់ដើម វិញ ។

មាត្រា ៧.- ការដាក់ចេញគោលនយោបាយប្រើប្រាស់ និង របៀបរបបនៃ ការប្រើប្រាស់ទឹកប្រាក់ដែលបានមកពីពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ ។

* * *

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩១ នាសម័យប្រជុំលើកទី ២០ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩១

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

...ត្រូវតាមច្បាប់ដើម

...ក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉ែន

Collection by VCAT Professional Consultant

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ: ១៧ ក្រ

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ
## នៃ
## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋ ប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតពន្ធលក្ខខាត ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបាន អនុម័តនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ក្នុងសម័យប្រជុំសាមញ្ញលើកទី ២០ នីតិកាលទី ១

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១
ជ.ក្រុមប្រឹក្សារដ្ឋ
ប្រធាន
អនុប្រធាន និង ប្រធានស្តីទី

ចំលងជូន

ក្រសួងព្រះបរមរាជវាំង
ក្រសួងរដ្ឋសភា
ទីស្តីការក្រុមប្រឹក្សារដ្ឋមន្ត្រី
គណៈកម្មការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ក្រោមក្រសួង
គណៈកម្មាធិការប្រជាជនខេត្ត ក្រុង

ទុកចូល
កាលប្បវត្តិ ឯកសារ

ថតចំលងត្រឹមត្រូវតាមច្បាប់ដើម
អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉េន